00718649

E99/3

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ចម្លើយទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការកំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ

ដាក់ដោយ៖

សហមេធាវីការពារក្ដីលោក ខៀវ សំផន

លោក ស សូវាន

លោក Jacques VERGES

ផ្ញើជូន៖

អង្គជំនុំជម្រះសាលាដំបូង

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ អុត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

សហព្រះរាជអាជ្ញា៖

លោកស្រី ជា លាង

លោក Andrew CAYLEY

មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណី ៖

លោក ពេជ្រ អង្គ

អ្នកស្រី Elisabeth SIMONNEAU FORT

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 07 / 2011
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានកែប្រែ ដីកាដំណោះស្រាយ[1] ជាពិសេសបានដកពាក្យ អំពើរំលោភសេពសន្ថវៈ ចេញពីកថាខណ្ឌ ១៦១៣ (វាក្យខណ្ឌ ឆ-ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ដោយសម្អាងថា "អំពើរំលោភសេពសន្ថវៈ មិនមាននៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ច្បាស់លាស់ឡើយ ក្នុងចន្លោះពេល ឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៩" តែបានចាត់ទុកថា "អង្គហេតុអាចត្រូវបានចាត់ទុកថាជា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបង្កឡើងដោយអំពើអមនុស្សធម៌ដទៃទៀត"។[2]

២. ដោយអនុលោមទៅតាម វិធាន៨០ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") គ្រប់ភាគីត្រូវបានស្នើសុំឱ្យឱ្យលើកឡើងពី អញ្ញត្រកម្មបឋមរបស់ខ្លួនលើយុត្តាធិការនៃអង្គជំនុំជម្រះ "យ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីដីកាបញ្ជូនរឿងទៅជម្រះចូលជាស្ថាពរ"។ លោក ខៀវ សំផន ក៏បានដាក់អញ្ញត្រកម្មរបស់លោក នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។[3]

៣. តាមរយៈបណ្ដឹង ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១[4] សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[5] អង្គជំនុំ

---

[1] ដីកាដំណោះស្រាយ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427

[2] ដីកាសម្រេចទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារលេខ 427/4/14 បទប្បញ្ញត្តិ កថាខណ្ឌ២ ២)

[3] អញ្ញត្រកម្មបឋមលើយុត្តាធិការ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារលេខ E46

[4] ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ។ ឯកសារនេះជាភាសាបារាំង មិនទាន់បានជូនជាដំណឹងនៅឡើយ។ ក្រុមមេធាវីការពារក្ដីបានបំពេញការងារ ដោយផ្អែកទៅលើឯកសារថតចម្លង ដែលផ្ញើជូននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

[5] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ E99

00718651

ជម្រះសាលាដំបូង បានទុកពេលឱ្យក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ចម្លើយ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។[6]

៤. នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ លោក អៀង សារី បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចជាបន្ទាន់ ទាក់ទងទៅ នឹងការទទួលយកសំណើសុំនេះ (ក្នុងចំណោមសំណើសុំផ្សេងទៀត) នៅក្នុងដំណាក់កាលនៃនីតិវិធីនេះ។[7]

៥. រហូតដល់ថ្ងៃនេះ អង្គជំនុំជម្រះ នៅមិនទាន់បានឆ្លើយតបទៅនឹងសំណើនេះឡើយ។

១. ការមិនទទួលយកបណ្តឹងរបស់សហព្រះរាជអាជ្ញា

៦. សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបានឡើយ ហើយត្រូវតែបានបដិសេធចោលតាំងពីដំបូងទី (*in limine*)។ ជាក់ស្តែង សំណើសុំនេះត្រូវបានដាក់ ដោយអនុវត្តនូវវិធាន ៩២ និង ៩៨ (២) នៃ វិធានផ្ទៃក្នុង"[8] ដែលវិធានទាំងពីរនេះមិនអាចអនុវត្តបានឡើយ ពោលគឺខុសអំពីវិធាន ៨៩ ដែលតាមរយៈ វិធាននេះ សហព្រះរាជអាជ្ញាបានបាត់បង់សិទ្ធរបស់ខ្លួនហើយ។

៧. វិធាន ៩៨ ដែលបានចំណងជើងថា "សាលក្រម" មិនអាចត្រូវបានប្រើជាមូលដ្ឋានគតិយុត្តិសម្រាប់ឱ្យ បណ្តឹងរបស់សហព្រះរាជអាជ្ញាអាចទទួលយកបាននោះឡើយ។ វិធាននោះបានចែងថា៖

> "២. សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ (...)
>
> ៣. អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុង

("សំណើរបស់សហព្រះរាជអាជ្ញា")

[6] ដីកាសម្រេចសុំពន្យារពេល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ ឯកសារលេខ D107

[7] សំណើរបស់លោក អៀង សារី សុំឱ្យមានសេចក្តីសម្រេចជាបន្ទាន់ ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឱ្យផ្លាស់ប្តូរការកំណត់បទចោទ នៅដំណាក់កាលនេះនៃនីតិវិធីដែរឬទេ និងសំណើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារលេខ E103។ សូមមើលការរំឭកនីតិវិធីទាក់ទងទៅនឹងការស្នើសុំជាច្រើនរបស់លោក អៀង សារី របៀបដូចគ្នានេះ។

[8] សំណើរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ១។

00718652

យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ។

(...)

៧. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ។

៨. កថាខណ្ឌ ២ អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែពុំបានអនុញ្ញាតដល់សហព្រះរាជអាជ្ញាឡើយ ក្នុងការផ្លាស់ប្តូរការកំណត់បទចោទ ក្នុងដំណាក់កាលនៃការចេញសាលក្រម "ក្នុងករណីដែលមិនមានដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទនោះ"។ ក្នុងដំណាក់កាលនៃការចេញសាលក្រមលើសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា បទបញ្ញត្តិនេះគឺជា "ការដាក់កម្រិតដល់អំណាចក្នុងការកំណត់សាជាថ្មីនូវបទចោទ ពោលគឺការផ្លាស់ប្តូរការកំណត់បទចោទថ្មីណាមួយមិនត្រូវធ្វើឲ្យលើសពីអង្គហេតុទាំងឡាយណាដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់នោះទេ"[9]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបន្ថែមទៀតផងដែរថា "វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទ បន្ទាប់ពីពេលចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះ"[10]។

៩. បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានលើកឡើងជាឯកសារយោង ចែងថា៖

"១. ដោយមិនធ្វើឲ្យលើសអំពីអង្គហេតុ និងកាលៈទេសៈដែលមានបង្ហាញនៅក្នុងឯកសារ ចោទប្រកាន់ និងក្នុងឯកសារកែប្រែអង្គហេតុណាមួយ អង្គជំនុំជម្រះអាចធ្វើការផ្លាស់ប្តូរ តាមរយៈសេចក្តីសម្រេចរបស់ខ្លួនស្របទៅនឹងមាត្រា ៧៤ នូវការកំណត់បទចោទ ដើម្បីឲ្យអង្គហេតុមានភាពស៊ីសង្វាក់គ្នាទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងក្នុងមាត្រា (...)

២. ប្រសិនជានៅក្នុងដំណាក់កាលណាមួយនៃការជំនុំជម្រះ អង្គជំនុំជម្រះយល់ឃើញ

---

[9] សាលក្រមក្នុងសំណុំរឿង ឌុច, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ *ឯកសារតុលាការ* E188 កថាខណ្ឌ៤៩៤។

[10] សាលក្រមក្នុងសំណុំរឿង ឌុច, កថាខណ្ឌ៤៩៥ (មិនមានគូសបន្ទាត់ក្នុងឯកសារដើម)។

ថា ការកំណត់បទចោទអាចត្រូវបានផ្លាស់ប្តូរ អង្គជំនុំជម្រះត្រូវធ្វើការជូនដំណឹងដល់ភាគីនៃនីតិវិធី អំពីលទ្ធភាពនេះ ហើយបន្ទាប់ពីបានពិនិត្យលើធាតុផ្សំនៃភស្តុតាង អង្គជំនុំជម្រះត្រូវផ្តល់លទ្ធភាព ក្នុងពេលវេលាមួយសមស្របដល់ភាគីក្នុងការធ្វើកំណត់សម្គាល់ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ (...)[11]។

១០. នៅពេលអានវិធាន ៩៨ នៃវិធានផ្ទៃក្នុង បទដ្ឋាន ៥៥ នៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងមាត្រា ៧៤ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វាជាក់ច្បាស់ណាស់ថា ចៅក្រមអាច ធ្វើការកំណត់បទចោទសាជាថ្មីនៅក្នុងដំណាក់កាលសវនាការលើអង្គសេចក្តី។ ការកំណត់បទចោទ សាជាថ្មី ដោយយោងទៅលើការពិនិត្យភស្តុតាង អាចអនុញ្ញាតឱ្យអង្គហេតុមានភាព**ស៊ីសង្វាក់គ្នា** ទៅនឹងការកំណត់បទចោទដែលត្រឹមត្រូវបំផុត ពោលគឺការកំណត់បទចោទដែលមានលក្ខណៈត្រឹមត្រូវ បំផុត ត្រូវបានកំណត់ត្រឹមត្រូវតាមច្បាប់ និងស្ថិតក្នុងយុត្តាធិការនៃសាលាជម្រះក្តី។ ក្នុងករណីផ្សេងពីនេះ សាលាជម្រះក្តីត្រូវប្រកាសយ៉ាងសាមញ្ញថា ខ្លួនគ្មានយុត្តាធិការទៅលើរឿងនេះឡើយ។

១១. ការកំណត់បទចោទសាជាថ្មីគឺជាប្រតិបត្តិការមួយ ដែលចៅក្រមផ្តល់នូវការកំណត់ត្រឹមត្រូវចំពោះ ទង្វើ ឬអង្គហេតុណាមួយ ពោលគឺពុំមែនជាប្រតិបត្តិការដែលចៅក្រមអាចកែប្រែនិយមន័យគតិយុត្តិ នៃបទល្មើស ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនឡើយ។

១២. ដោយឡែក ប្រហែលជាផ្អែកទៅលើប្រតិបត្តិការក្រោយនេះហើយ ដែលសហព្រះរាជអាជ្ញាបានស្នើសុំ ដល់អង្គជំនុំជម្រះសាលាដំបូងសម្រេចតាមសំណើសុំរបស់ខ្លួន។ សហព្រះរាជអាជ្ញាស្នើសុំដល់អង្គជំនុំជម្រះ សម្រេចអំពី**ច្បាប់ដែលត្រូវអនុវត្ត**ទៅលើសាលាជម្រះក្តី ដោយស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចលើការចោទសួរ ថាតើការរំលោភសេពសន្ថវៈមានលក្ខណៈជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាក់លាក់ដែរឬទេ រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

១៣. ចំពោះសហព្រះរាជអាជ្ញា "ការស្នើសុំឱ្យកំណត់ឡើងវិញនេះ គ្រាន់តែពាក់ព័ន្ធទៅនឹង<u>ការកែ</u>

---

[11] មាត្រា ៧៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម ("អំពីល័ក្ខខ័ណ្ឌតម្រូវសម្រាប់សេចក្តីសម្រេច") ចែងនៅក្នុងកថាខណ្ឌ២ ថា៖ "សេចក្តីសម្រេចរបស់សភាជំនុំជម្រះ ត្រូវផ្អែកលើការវាយតម្លៃរបស់ខ្លួន លើភ័ស្តុតាង និងដំណើរការជម្រះរឿងក្តីទាំងមូល។ សេចក្តីសម្រេច មិនត្រូវធ្វើឲ្យហួសពីអង្គហេតុ និងកាលៈទេសៈដែលបានពណ៌នានៅក្នុងបទចោទប្រកាន់ និងក្នុងការកែប្រែបទចោទប្រកាន់នានា។ តុលាការអាចផ្អែកលើសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភ័ស្តុតាងដែលបានដាក់ជូន និងបានពិភាក្សានៅចំពោះមុខតុលាការ ក្នុងពេលជំនុំជម្រះប៉ុណ្ណោះ"។

សម្រួលលើក្របខណ្ឌការងារ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ ក្នុងការវាយតម្លៃលើអង្គហេតុនានា ដែលមានរួចទៅហើយ នៅចំពោះមុខតុលាការតែប៉ុណ្ណោះ។ [12] ប៉ុន្តែការវាយតម្លៃអង្គហេតុ ធ្វើឡើងតែនៅក្នុងក្របខណ្ឌនៃច្បាប់អនុវត្តន៍ ដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះ កែតម្រូវ និងកែប្រែតែប៉ុណ្ណោះ។

១៤. ការភ័ន្តច្រឡំរបស់សហព្រះរាជអាជ្ញាកាន់តែឃើញច្បាស់ថែមទៀត នៅពេលដែលសហព្រះរាជអាជ្ញាអះអាងថា "ការកំណត់បទចោទទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈបានកែប្រែរួចមកហើយ គឺចន្លោះពេលនៃការចេញដីកាដំណោះស្រាយដើម និងដីកាដំណោះស្រាយដើមដែលបានធ្វើសវនកម្ម"។ [13] ក៏ប៉ុន្តែ មិនមែនការកំណត់បទចោទនោះទេ ដែលត្រូវបានធ្វើវិសោធនកម្មដោយ អង្គបុរេជំនុំជម្រះ ៖ នៅពេលលុបចោលវាក្យខណ្ឌស្តីពីការរំលោភសេពសន្ថវៈ ពីក្នុងកថាខណ្ឌទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គបុរេជំនុំជម្រះបានកែប្រែវិសាលភាពនៃច្បាប់អនុវត្តន៍ (ឬ "កែតម្រូវក្របខណ្ឌ" ជាពាក្យដែលប្រើប្រាស់ដោយ សហព្រះរាជអាជ្ញា)។

១៥. ក្នុងករណីជាក់ស្តែង វិធាន ៩៨ (២) ពុំត្រូវបានអនុវត្តឡើយ គឺដូចគ្នាទៅនឹងវិធាន ៩២ ដែរ[14]។ ផ្ទុយទៅវិញ បទបញ្ញត្តិពិសេសអនុញ្ញាតឲ្យភាគីធ្វើការស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការកំណត់និយមន័យ គតិយុត្តិនៃបទល្មើស ឬនៃបែបផែននៃការចូលរួម របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ពោលគឺកំណត់អំពីច្បាប់ដែលអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ៖ ករណីនេះពាក់ព័ន្ធទៅនឹងវិធាន ៨៩ ដែលចែងអំពីអញ្ញត្រកម្មយុត្តាធិការរបស់ អ.វ.ត.ក.។ មានតែវិធាន ៨៩ និងគោលការណ៍នីត្យានុកូលភាពមួយគត់ ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើបទល្មើស និងបែបផែននៃការចូលរួមដូចដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថាតើស្ថិតនៅក្រោម ឬមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួននោះ។

១៦. ជាក់ស្តែង ការស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីអត្ថិភាពនៃចំណងពាក់ព័ន្ធជាមួយ

---

[12] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៩ (នៅក្នុងច្បាប់ដើម មិនមានគូសបន្ទាត់ពីក្រោមទេ)

[13] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១១

[14] ទោះបីជាវិធាន ៩២ អនុញ្ញាតឲ្យភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ រហូតដល់ពេលបិទបញ្ចប់ការពិភាក្សាដេញដោលក៏ដោយ ក៏វិធាននេះមិនបានបញ្ជាក់ពីប្រភេទនៃសេចក្តីសន្និដ្ឋានបែបណាដែរ។ វិធាននេះជាបញ្ញត្តិទូទៅដែលត្រូវអនុវត្តនៅពេល ពុំមានបញ្ញត្តិពិសេស។

00718655

នឹងការរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ជាក់លាក់រវាងឆ្នាំ១៩៧៥ ដល់១៩៧៩ ដោយផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានសេចក្តីថា ស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការសម្រេចអំពីច្បាប់ដែលត្រូវអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ ហើយស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះ។

១៧. ជាក់ស្តែង សហព្រះរាជអាជ្ញាពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់នូវអញ្ញត្រកម្មបឋមរបស់ ខ្លួនពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះក្នុងរយៈពេល ៣០ ថ្ងៃ នៅឡើយទេ ដែលបន្ទាប់ពីផុតរយៈពេលនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងចូលជាស្ថាពរ ដូចបានកំណត់ក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុង "ផុតរយៈពេលនេះ អញ្ញត្រកម្មបឋមមិនអាចទទួលយកបានឡើយ"។ ជាក់ស្តែង សំណើសុំរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ពោលគឺមាន រយៈពេលជាងបួនខែក្រោយរយៈពេលផុតកំណត់ដែលចែងដោយវិធានផ្ទៃក្នុង។ ដូច្នេះសំណើសុំនោះ មិនអាចទទួលយកបានឡើយ។

១៨. ជាក់ស្តែង សហព្រះរាជអាជ្ញាមានបំណងធ្វើបណ្តឹងឧទ្ធរណ៍ "ក្លែងក្លាយ" ប្រឆាំងទៅនឹងដីកាដំណោះស្រាយ និងប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

១៩. ដោយឡែក អង្គបុរេជំនុំជម្រះបានរំលឹកតាមរយៈសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ថា៖ "ដោយអនុវត្តវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះជាសេចក្តីសម្រេច បិទផ្លូវតវ៉ា"។សហព្រះរាជអាជ្ញាក៏បានទទួលស្គាល់ចំណុចនេះផងដែរ ដោយបានលើកឡើងកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ ក្នុងសវនាការសម្រេចអំពីការដោះលែងឱ្យនៅក្រៅឃុំ ថា៖

> "សំណើសុំនេះមិនអាចទទួលយកបានឡើយ ដោយហេតុថាសំណើសុំនេះបានស្នើសុំឱ្យអង្គសវនាការធ្វើ ការ<u>ពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ</u> ហើយស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការ កំណត់អំពីសុពលភាពនៃសេចក្តីសម្រេចនេះ ដែលចេញថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។
>
> វិធានផ្ទៃក្នុងរបស់តុលាការ នៅត្រង់វិធាន៧៧ (១៣) បានចែងយ៉ាងច្បាស់ថា <u>សេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយគេពុំចាំបាច់ធ្វើការបញ្ជាក់នៅទីនេះថាអង្គជំនុំជម្រះសាលាដំបូងពុំត្រូវបានបង្កើតក្នុង ក្របខណ្ឌនៃវិធានផ្ទៃក្នុង ឱ្យដើរតួនាទីជាសាលាឧទ្ធរណ៍នោះទេ</u>។ យើងសូមប្រកាសថា ទោះបីជាមានការយល់ឃើញថា ទឡ្ហីករណ៍ដែលលើកឡើងដោយ នួន ជា មានតម្លៃយ៉ាងណាក៏ដោយ ក៏សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនអាចត្រូវបានពិនិត្យឡើងវិញ ដោយអង្គជំនុំជម្រះសាលាដំបូងដែរ <u>ហើយអង្គជំនុំជម្រះសាលា</u>

ដំបូងពុំមានយុត្តាធិការក្នុងរឿងនេះទេ[15]"។

២០. ដោយសារតែបណ្តឹងរបស់សហព្រះរាជអាជ្ញា បង្ហាញយ៉ាងជាក់ថាមិនអាចទទួលយកបាន ដូច្នេះ លោក ខៀវ សំផន មិនឆ្លើយតបឲ្យបានលម្អិតទៅនឹងអំណះអំណាងដែលបានលើកឡើងនោះឡើយ។

. អំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

២១. សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ដកសេចក្តីសម្រេច ដែលថាអំពើរំលោភសេពសន្ថវៈ មិនមាននៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ច្បាស់លាស់ឡើយ ក្នុងចន្លោះពេល ឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៩ ដោយសម្អាងថា អំពើរំលោភសេពសន្ថវៈ មាននៅក្នុងច្បាប់ប្រពៃណីអន្តរជាតិ ដែលគេចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ យ៉ាងជាក់ច្បាស់ នៅក្នុងសម័យកាលនេះ។ [16]

២២. លោក ខៀវ សំផន សូមភ្ជាប់ទៅនឹងអំណះអំណាងដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង។[17] លោកបានបង្ហាញថា ប្រភពឯកសារដែលលើកឡើងដោយ សហព្រះរាជអាជ្ញាអាចឲ្យគេធ្វើសេចក្តីសន្និដ្ឋានថា អំពើរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មសង្គ្រាមមុនឆ្នាំ ១៩៧៥ និងមិនមែនជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ [18]

២៣. ដោយសារតែមិនអាចផ្តល់នូវប្រភព ដែលមានទំនោរទៅរកការអះអាងបញ្ជាក់ពីការចោទប្រកាន់តាមទម្លាប់ប្រពៃណីចំពោះ អំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មុន ឬក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ សហព្រះរាជអាជ្ញាក៏ភាន់ភាំងក្នុងការប៉ាន់ស្មានរបស់ខ្លួន។

២៤. បើតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា ការដែលថាធាតុផ្សំនៃភស្តុតាងពាក់ព័ន្ធទៅនឹងអំពើរំលោភសេពសន្ថវៈ ដែលបង្ហាញដោយព្រះរាជអាជ្ញានៅក្នុងតុលាការ Nuremberg

---

[15] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសំណើសុំឲ្យដោះលែង "នួន ជា, អៀង ធីរិទ្ធ និង ខៀវ សំផន" ជាបន្ទាន់ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ *ឯកសារតុលាការ* E1/1.1 ទំព័រ ៤៧ ចាប់ពីបន្ទាត់ ៩ ដល់ ២៥ [លេខទំព័រក្នុងប្រតិចារឹក ជាភាសាបារាំង] មិនមានគូសបន្ទាត់ពីក្រោមនៅក្នុងឯកសារដើម។

[16] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១២ ដល់ទី២១

[17] ដីកាសម្រេចទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ មេសា ឆ្នាំ ២០១១ ឯកសារតុលាការ D427/1/30 កថាខណ្ឌទី៣៦៤ ដល់ទី ៣៧០

[18] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១២ ដល់ទី១៣

00718657

មិនត្រូវបានរាប់បញ្ចូល "ដោយចេតនា" គឺវា "*ហាក់ដូចជា* ដោយសារតែមានបញ្ហាកំហិតក្នុងពេលអនុវត្ត"។[19] មតិវាយស្លានសុទ្ធសាធនេះ មិនមានអ្វីប្លែកឡើយ ពីព្រោះថា អំពើរំលោភសេពសន្ថវៈ ពុំមានចែងនៅក្នុងលក្ខន្តិកៈនៃតុលាការ Nuremberg នោះឡើយ។ ម៉្យាងវិញទៀត មហាសន្និបាតនៃអង្គការសហប្រជាជាតិ មិនបានរាប់បញ្ចូល អំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នោះឡើយ នេះគឺដើម្បីជាការបញ្ជាក់បន្ថែមទៅលើគោលការណ៍នៃតុលាការ Nuremberg ។[20]

២៥. បើតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាដដែល ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនមានបញ្ជាក់ច្បាស់ថា ត្រង់ចំណុចណាដែលធ្វើឱ្យអំពើរំលោភសេពសន្ថវៈក្លាយទៅជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់អន្តរជាតិក្តី "*រឿងនោះអាចនឹងកើតមានឡើង* មុនការផ្ទុះឡើងនៃសង្គ្រាមលោកលើកទី២ ព្រោះថាមិនមានការវិវត្តខ្លាំងក្លាទេ ទាក់ទងនឹងអនុសញ្ញា ឬយុត្តិសាស្ត្រ ចំពោះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រវាងឆ្នាំ ១៩៤៥ និងឆ្នាំ១៩៩៣"។ [21] ការសន្មតនេះ មិនត្រឹមតែជារឿងចៃដន្យប៉ុណ្ណោះទេ តែការលើកមូលហេតុនេះ ពង្រឹងថែមទៀតទៅលើគំនិតដែលថា អំពើរំលោភសេពសន្ថវៈមិនត្រូវបានចោទប្រកាន់ថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងកំឡុងពេលនោះទៀតផង។ ពីព្រោះថា ការអនុវត្តទូទៅនៃរដ្ឋទាំងឡាយ និងទស្សនៈច្បាប់ (*Opinio juris*) មិនអាចមានប្រភពចេញពីអវត្តមាននៃការវិវត្តអនុសញ្ញា និងយុត្តិសាស្ត្រ និងពីច្បាប់ទី១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យនោះឡើយ។ [22]

២៦. ផ្ទុយទៅវិញ ការរំលោភសេពសន្ថវៈ អាចត្រូវបានដាក់ឲ្យទៅជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងពេលមុននោះ គឺមុនពេលអនុម័តលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ្វាន់ដា។ ទាំងអស់នេះអាចបកស្រាយថាជាតម្រូវការចាំបាច់ ដែលគេត្រូវសម្របខ្លឹមសារនៃបទដ្ឋាននៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្ស

[19] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៥ (នៅក្នុងច្បាប់ដើម មិនមានគូសបន្ទាត់ពីក្រោមទេ)

[20] ដីកាសម្រេចទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ មេសា ឆ្នាំ ២០១១ ឯកសារតុលាការ D427/1/30 កថាខណ្ឌទី៣៦៨

[21] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៨ (នៅក្នុងច្បាប់ដើម មិនមានគូសបន្ទាត់ពីក្រោមទេ)

[22] ដីកាសម្រេចទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ មេសា ឆ្នាំ ២០១១ ឯកសារតុលាការ D427/1/30 កថាខណ្ឌទី៣៦៨។ ម៉្យាងទៀត អង្គបុរេជំនុំជម្រះ បានលើកឡើងពេលមុននោះ នៅក្នុងកថាខណ្ឌទី៣០៩ ថាជាច្បាប់ផ្ទៃក្នុង។

00718658

ជាតិ ទៅនឹងប្រភេទនៃជម្លោះ ដែលមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្លា។

២៧. បើតាមប្រសាសន៍របស់លោក អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៩៤ ៖ "ប្រសិនបើខ្លឹមសារបទដ្ឋាននៃសញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅមានទម្រង់ដដែលឥតប្រែប្រួល ដូចនៅក្នុងលក្ខន្តិកៈនៃតុលាការ Nuremberg ខ្លឹមសារនោះមិនអាចយកទៅអនុវត្តសម្រាប់ស្ថានភាព នៅប្រទេសរ្វាន់ដា រវាងថ្ងៃទី៦ ខែមេសា និងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ បានឡើយ។ [23]

២៨. ម៉្យាងទៀត នៅក្នុងលិខិតដែលផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ដដែលនោះ លោកអគ្គលេខាធិការបានដាក់បញ្ជីអំពើនានា ដែលគណៈកម្មការជំនាញស្តីពីប្រទេសរ្វាន់ដាចាត់ចូលក្នុងសញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ ការរំលោភសេពសន្ថវៈមិនមាននៅក្នុងបញ្ជីនោះទេ។ [24]

២៩. ការបញ្ចូលនានាពេលថ្មីៗ នូវអំពើរំលោភសេពសន្ថវៈ ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបកស្រាយបង្ហាញ តាមរយៈការវិភាគការងារស្រាវជ្រាវ នៃគណៈកម្មការច្បាប់អន្តរជាតិ (CDI) ពាក់ព័ន្ធនឹងគម្រោងតាក់តែងក្រមនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ។ ពីព្រោះថា គេច្រើនតែកត់សម្គាល់ឃើញថា អំពើរំលោភសេពសន្ថវៈដែលគេចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានឃើញនៅក្នុងគម្រោងនៅឆ្នាំ១៩៩៦ នេះប៉ុណ្ណោះ គឺថាគណៈកម្មការច្បាប់អន្តរជាតិបានធ្វើការសង្កេតជាលក្ខណៈប្រព័ន្ធ ទៅលើអំពើរំលោភសេពសន្ថវៈ នៅក្នុងពេលជម្លោះនាពេលថ្មីៗនេះ។ [25]

---

[23] លិខិតចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩៤ ដែលលោកអគ្គលេខាធិការ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារលេខ S/1994/1125 ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៩៤ កថាខណ្ឌទី១១៣

[24] លិខិតចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩៤ ដែលលោកអគ្គលេខាធិការ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារលេខ S/1994/1125 ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៩៤ កថាខណ្ឌទី១១៨។ ក្រោយមក លោកអគ្គលេខាធិការបានកត់សម្គាល់ថា "នៅក្នុងលក្ខន្តិកៈនៃ [តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសរ្វាន់ដា] លោកអគ្គលេខាធិការបាននិយាយជ្រៅជាងក្នុងលក្ខន្តិកៈនៃ [តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសយូហ្គោស្លាវី] ទៅទៀត នៅក្នុងជម្រើសច្បាប់អនុវត្តន៍ ហើយលោកបានបញ្ចូលទៅក្នុងយុត្តាធិការលើរឿងក្តី (rationae materiae) នូវលិខិតូបករណ៍ដែលអាចមិនត្រូវបានចាត់ទុកថាស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ » របាយការណ៍បង្ហាញដោយ លោកអគ្គលេខាធិការដោយអនុលោមតាមកថាខណ្ឌទី៥ នៃដំណោះស្រាយ ៩៥៥ (១៩៩៤) នៃក្រុមប្រឹក្សាសន្តិសុខ S/1995/134 ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌទី៧

[25] គម្រោងតាក់តែងក្រមនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ និងសេចក្តីអធិប្បាយទៅលើចំណុចនេះ គឺជាឯកសារច្បាប់ដែលត្រូវបានអនុម័តដោយគណៈកម្មការ នាសម័យប្រជុំលើកទី៤៨ នៅឆ្នាំ១៩៩៦ ទំព័រ ៥២-

ចម្លើយទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ

៣០. ការបញ្ចូលនានាពេលថ្មីៗ នូវការចោទប្រកាន់អំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានអះអាងបញ្ជាក់ដោយការខ្វែងគំនិតគ្នារវាងយុត្តិសាស្ត្រទី១នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសរ្វាន់ដា តុលាការព្រហ្មទណ្ឌអន្តរជាតិ ស្តីពីវិសាលភាពនៃសញ្ញាណ[26] (ហើយពុំមែនជា "សភាពថេរនៃសេចក្តីសន្និដ្ឋាន" ដែលលើកឡើងដោយសហព្រះរាជអាជ្ញានោះឡើយ)។ [27]

៣១. ទីបញ្ចប់ សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិនិត្យលើសេចក្តីសម្រេច ធ្វើឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាប់ពីឆ្នាំ១៩៩៨[28] ដើម្បីកំណត់អត្ថិភាពនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ រវាងឆ្នាំ១៩៧៥ និង១៩៧៩។[29]

៣២. ក៏ប៉ុន្តែ ប្រសិនបើ អង្គជំនុំជម្រះណាមួយ អាចផ្អែកទៅលើសេចក្តីសម្រេចនៃតុលាការអន្តរជាតិមុនៗ ដើម្បីគោរពគោលការណ៍នីត្យានុកូលភាព ក៏ព្រោះតែសេចក្តីសម្រេចទាំង

---

៥៣ ៖ "អត្ថបទ និងស្នាដៃផ្សព្វផ្សាយរាប់មិនអស់ ដែលលើកឡើងពីស្ថានភាពនៃអំពើរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តទៅជាលក្ខណៈប្រព័ន្ធ ឬជាលក្ខណៈទ្រង់ទ្រាយធំ នៅអតីតប្រទេសយូហ្គោស្លាវី (...) លើសពីនោះទៅទៀត នៅឆ្នាំ១៩៩៤ គណៈកម្មការជាតិដើម្បីសច្ចភាព និងយុត្តិធម៌ បានធ្វើសេចក្តីសន្និដ្ឋានចេញពីការអង្កេតមួយ ដោយអះអាងថា អំពើហិង្សាផ្លូវភេទ ដែលប្រព្រឹត្តទៅនៅកោះ ហៃទី ក្រោមរូបភាពជាការរំលោភសេពសន្ថវៈជាលក្ខណៈប្រព័ន្ធ ដោយសារមូលហេតុនយោបាយ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"។ លើសពីនោះ គណៈកម្មការច្បាប់អន្តរជាតិ បានយោងទៅលក្ខន្តិកៈនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសរ្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសយូហ្គោស្លាវី។

[26] ជាឧទាហរណ៍ សូមមើល ការខ្វែងគំនិតគ្នារវាង ៖ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសរ្វាន់ដា *សហព្រះរាជអាជ្ញា c. Akayesu* លេខ ICTR-96-4-T ការកាត់សេចក្តី ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌទី១៣០ និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសយូហ្គោស្លាវី *សហព្រះរាជអាជ្ញា c. Furundzija* លេខ IT-95-17/1-T ការកាត់សេចក្តី ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌទី១២៧ និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសយូហ្គោស្លាវី *សហព្រះរាជអាជ្ញា c. Kunarac et autres*, លេខ IT-93-23&IT-96-23/1-A, សាលដីកា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌទី១៣០។

[27] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី២១

[28] តុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីអតីតប្រទេសរ្វាន់ដា *សហព្រះរាជអាជ្ញា c. Akayesu* លេខ ICTR-96-4-T ការកាត់សេចក្តី ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ គឺជារឿងក្តីទី១ ដែលនៅក្នុងនោះ ការរំលោភសេពសន្ថវៈ ត្រូវបានចោទប្រកាន់នៅចំពោះមុខ តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលគេចាត់ចូលជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សូមមើល សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៧។

[29] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី១៩ ដល់ទី២១។

នោះ "មិនបានហាមឃាត់អង្គជំនុំជម្រះមិនឲ្យផ្អែកលើសេចក្ដីសម្រេចដែលសមស្រប ដែលសេចក្ដីសម្រេចនោះបកស្រាយអំពីធាតុផ្សំជាក់លាក់នៃបទល្មើសណាមួយនោះដែរ"[30] ឬក៏សេចក្ដីសម្រេចទាំងនោះអាចឲ្យគេ "បកស្រាយបំភ្លឺចំពោះធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់ណាមួយនោះ"។[31]

៣៣. អាចនិយាយម្យ៉ាងទៀតថា គោលការណ៍ដែលចេញពីយុត្តិសាស្ត្រមុនៗ នៃតុលាការ អន្តរជាតិ អាចយកទៅប្រើប្រាស់ ដើម្បីបញ្ជាក់ពីធាតុផ្សំសម្ភារៈ និងធាតុផ្សំផ្លូវចិត្តនៃបទល្មើស។ គោលការណ៍ទាំងនោះ មិនអាចឲ្យគេដឹងថា តើវាជាបទល្មើសដែលចេញពីយុត្តាធិការនៃអង្គជំនុំជម្រះ ឬអត់នោះឡើយ។

៣៤. ជាសន្និដ្ឋាន សហព្រះរាជអាជ្ញាមិនបានបកស្រាយថា ការរំលោភសេពសន្ថវៈ ត្រូវបានចទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងជាក់លាក់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ រវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ឡើយ។

ហេតុដូច្នេះ

៣៥. សូមឲ្យអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- ប្រកាសមិនទទួលយកការស្នើសុំរបស់សហព្រះរាជអាជ្ញា
- ជាសេចក្ដីបន្ទាប់បន្សំ សូមទាត់ចោល ការស្នើសុំរបស់សហព្រះរាជអាជ្ញា

[30] សាលក្រមឌុច កថាខណ្ឌទី៣៥។

[31] ដូចខាងលើ កថាខណ្ឌទី២៩០។

ក្រុមសិទ្ធិកែប្រែគ្រប់យ៉ាង
និងដើម្បីយុត្តិធម៌

	មេធាវី ស សូវាន មេធាវី Jacques VERGÈS	ភ្នំពេញ ប៉ារីស	[signatures]
កាលបរិច្ឆេទ	ឈ្មោះ	ទីកន្លែង	ហត្ថលេខា